**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**

**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

លេខៈ..............០៣១/២៧........គ.ផ.ប/ស ជ ៣

# សេចក្តីជូនដំណឹង

## ស្តីពីនីតិវិធីនៃការបញ្ជាក់អត្តសញ្ញាណ

## ជូនពលករកម្ពុជាដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់បានជ្រាបថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជាដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC)ដែលមានព័ត៌មានដូចខាងក្រោម៖

**I. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា**

១.ទីកន្លែង ៖

- ទីក្រុងបាងកក៖ អាសយដ្ឋាន អ៊ីមផើរៀល វើល ឡាតប្រាវ (Imperial World Ladphrao) ជាន់ទី៤, លេខ២៥៣៩, ច្រក៨១-៨៣ ផ្លូវឡាតប្រាវ, សង្កាត់ ចៅឃុនស៊ីង, ខណ្ឌ ប៉ុងឡាង, ទីក្រុងបាងកក ១០៣១០
- ខេត្តរ៉ាក់យ៉ង . អាសយដ្ឋាន ផ្សារ អូថប់ម៉ាយ៉ង (OTOP MA YONG) -២០១ភូមិ ៧, ឃុំ ម៉ាខាមឃូ, ស្រុក និឃុំផាត់តាណា, ខេត្ត រ៉ាក់យ៉ង ២១១៨០
- ខេត្តសុងក្លា ៖ អាសយដ្ឋាន ផ្សារ ហ្វុកទៀន(Fuk Thian), ៩៩ភូមិ៣, ឃុំ ខ្លងហែរ, ស្រុក ហ៉ាត់យៃ, ខេត្ត សុងក្លា

២.ថ្ងៃម៉ោងធ្វើការ ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

៣.តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នាគឺ ២ ៣៥០ (ពីរពាន់បីរយហាសិប)បាត។

**II.ឯកសារតម្រូវសម្រាប់ពលករមកស្នើសុំធ្វើលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស**

១.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ច្បាប់ដើម និងច្បាប់ថតចម្លងចំនួន២ច្បាប់

២.ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ឬលិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករដែលចេញដោយក្រសួងការងារថៃ ឬមន្ទីរការងារថៃច្បាប់ដើម និងច្បាប់ថតចម្លងចំនួន២ច្បាប់

៣.ប័ណ្ណអនុញ្ញាតការងារផ្នែកនេសាទ (សម្រាប់ពលករផ្នែកនេសាទ)

៤.ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក

៥.ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

**III.អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំមិនយកតម្លៃសេវា**

១. ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២. សំបុត្រកំណើតកូន ឬសំបុត្រពេទ្យ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**